**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**"រ.ទ.ស.ភ"**
លេខ .....................

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី១៤ អាណត្តិទី៥ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ចាប់ពីម៉ោង ០៨ និង ៣០ នាទីព្រឹក នៅស្នាក់ការរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ **ឯកឧត្តម សឹម ណារ៉ា** ជាប្រធានក្រុមប្រឹក្សាភិបាលនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៥ បានអញ្ជើញចូលរួមជាអធិបតីដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៤ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ(រ.ទ.ស.ភ)។

នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី១៤ នេះ អង្គប្រជុំបានពិនិត្យ និងពិភាក្សាយ៉ាងផុសផុលលើខ្លឹមសារលម្អិតនៃរបាយការណ៍របស់ រ.ទ.ស.ភ ដោយបាន**ទទួលជ្រាបជារបាយការណ៍** និង**អនុម័ត** ដូចខាងក្រោម៖

- របាយការណ៍លទ្ធផលហិរញ្ញវត្ថុ ឆ្នាំ២០១៤ (ក្រោយសវនកម្ម) ដែលមានប្រាក់ចំណេញក្រោយបង់ពន្ធចំនួន ៤៥.៧៤៧.៩១១.០០០រៀល

- គោលការណ៍បែងចែកប្រាក់ចំណេញ ឆ្នាំ២០១៤
  - បង្កើតភាគបំរុងតាមច្បាប់ចំនួន ៥% មានទឹកប្រាក់ចំនួន ២.២៨៧.៣៩៥.៥៥០រៀល
  - បង្កើតភាគបំរុងសេរីចំនួន ៥% មានទឹកប្រាក់ចំនួន ២.២៨៧.៣៩៥.៥៥០រៀល
  - ប្រាក់ចំណេញរក្សាទុក មានទឹកប្រាក់ចំនួន ៣២.០២៣.៥៣៧.៧០០រៀល
  - បែងចែកភាគលាភដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ ៖
    - អនុបាតនៃការបែងចែកភាគលាភ ចំនួន ២០%
    - ភាគលាភសរុបដែលត្រូវបែងចែក មានទឹកប្រាក់ចំនួន ៩.១៤៩.៥៨២.២០០រៀល
    - ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ ចំនួន ១០៥,២០រៀល/ភាគហ៊ុន
    - កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ: ១៣ មេសា ២០១៥
    - កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ: ២៤ មេសា ២០១៥

- កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៣ ៖
  - កាលបរិច្ឆេទកំណត់ទុក (Record Date): ១៣ មេសា ២០១៥
  - កាលបរិច្ឆេទកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី៣: ២៧ មេសា ២០១៥
  - ពេលវេលា: ម៉ោង ០៨:០០ ដល់ ម៉ោង ១១:០០
  - ទីកន្លែងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី៣: សាលប្រជុំធំ( ស្នាក់ការរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ)
  - របៀបវារៈសំខាន់ៗ៖ បទបង្ហាញស្តីពី លទ្ធផលអាជីវកម្មឆ្នាំ២០១៤ និងទិសដៅអាជីវកម្មឆ្នាំ២០១៥



ទីស្នាក់ការ : លេខ ៤៥ ផ្លូវ ១០៦ សង្កាត់ ស្រះចក ខណ្ឌ ដូនពេញ, ទូរស័ព្ទ: ០២៣-៧២៤-០៤៦ Email: admin@ppwsa.com.kh

- សមាសភាពនៃគណៈកម្មាធិការសវនកម្ម
  - លោក អោម សេងបូរ៉ា អភិបាលឯករាជ្យ ជាប្រធាន
  - ឯកឧត្តម នេត មុន្នី មន្ត្រីត្រួតពិនិត្យរដ្ឋ ជាអនុប្រធាន
  - លោកស្រី ងិន ចន្ទ្រា អភិបាលតំណាងនិយោជិត រ.ទ.ស.ភ ជាសមាជិក
- សមាសភាពនៃគណៈកម្មាធិការគ្រប់គ្រងហានិភ័យ
  - ឯកឧត្តម ម៉ី វ៉ាន់ អភិបាលតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន
  - ឯកឧត្តម ស៊ឹម ស៊ីថា អគ្គនាយក រ.ទ.ស.ភ ជាអនុប្រធាន
  - ឯកឧត្តម ឃួង ស្រេង អភិបាលតំណាងសាលារាជធានីភ្នំពេញ ជាសមាជិក
  - លោកឧកញ៉ា ចាង យុនហ្វេង អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ជាសមាជិក
  - លោក ជូ ផល្លា ប្រធានអង្គភាពលទ្ធកម្ម ជាសមាជិក
- ស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើ "អាករលើតម្លៃបន្ថែម លើថ្លៃប្រើប្រាស់ទឹក ស្មើអត្រាសូន្យ"

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ០៦:០០ នាទីល្ងាច នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសទទួលខុសត្រូវខ្ពស់ និងឯកភាពគ្នា។

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**